សាកលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

សារណាបញ្ចប់ការសិក្សា

ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Tesla, Inc.

ស្រាវជ្រាវចាប់ពីថ្ងៃ ៨ មេសា ២០២៤ ដល់ថ្ងៃទី ១០ សីហា ២០២៤

ស្រាវជ្រាវដោយ
និស្សិត លោក **ហុន លាងស៊ី**
កញ្ញា **ឈូក ចន្ធូ**

ណែនាំដោយ
លោក **ជា ម៉ែងសៃ**

ថ្នាក់បរិញ្ញាប័ត្រ **គណនេយ្យ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

សេចក្តីថ្លែងអំណរគុណ

ក្នុងនាមខ្ញុំបាទឈ្មោះ **ហុន លាងស៊ី** និងនាងខ្ញុំឈ្មោះ **ឈូក ចន្ធូ** ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគណនេយ្យ ក្រុម A4C1 និង A4C2 ជំនាន់ទី **១៩** ឆ្នាំសិក្សា **២០២៣-២០២៤** ដែលបានសិក្សាស្រាវជ្រាវលើប្រធានបទ " ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Tesla, Inc."។ សូមសម្តែងនូវសេចក្តីគោរព និងការដឹងគុណដល់បុគ្គលសំខាន់ៗដូចខាងក្រោម ៖

លោកឪពុក និងអ្នកម្តាយ ដែលជាអ្នកមានគុណដ៏ធំធេងរបស់យើងខ្ញុំទាំងពីរនាក់ ដែលបានលះបង់ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅកូនឲ្យគោរពប្រតិបត្តិតាមគន្លងធម៌។ ពោលគឺលោកទាំងទ្វេបានផ្តល់នូវម្លប់ដ៏ត្រជាក់ប្រកបទៅដោយព្រហ្មវិហារធម៌ទាំងបួនតាំងពីកូនបានចាប់កំណើតហូតដល់បច្ចុប្បន្ន ជាពិសេសលោកទាំងពីរបានជួយទំនុកបម្រុងគ្រប់បែបយ៉ាង ដើម្បីឲ្យកូនបានសិក្សាមានចំណេះដឹងជ្រៅជ្រះរហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យយ៉ាងត្រចះត្រចង់នេះ។

ឯកឧត្តមបណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកគ្រប់លំដាប់ជាន់ថ្នាក់ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏ មានតម្លៃខិតខំប្រឹងប្រែងបង្ហាត់បង្រៀន ប្រៀនប្រដៅ អប់រំទូន្មាន ណែនាំអស់ពីកម្លាំងកាយចិត្តដល់យើងខ្ញុំក្នុងរយៈពេលបួនឆ្នាំកន្លងមកនេះ ដោយពុំគិតពីការនឿយហត់ និងទុក្ខលំបាកនោះឡើយ។

លោកគ្រូ **ជា ម៉ែងសៃ** ដែលជាលោកគ្រូណែនាំនូវកិច្ចការស្រាវជ្រាវរបស់យើងខ្ញុំ។ លោកគ្រូតែងតែផ្តល់នូវកម្លាំងចិត្ត អប់រំ ដាស់តឿន ក្រើនរំលឹក ថែមទាំងចំណាយពេលវេលាដ៏មានតម្លៃក្នុងការអប់រំ ណែនាំ ផ្តល់នូវគំនិតល្អៗ និងចំណេះដឹងជាច្រើនសម្រាប់យើងខ្ញុំយ៉ាងអស់អំពីចិត្ត ព្រមទាំងជួយកែសម្រួលនូវ ចំណុចខ្វះខាតដែលបានកើតមានឡើងលើសារណាមួយនេះផងដែរ។

បងប្អូន ប្រុសស្រី មិត្តភក្តិ ព្រមទាំងមិត្តរួមថ្នាក់ទាំងអស់ដែលបានផ្តល់ជាកម្លាំងចិត្តក្នុងការសរសេរសារណានេះឡើង និងផ្តល់ជាមតិ រិះគន់ដើម្បីស្ថាបនារាល់កំហុសឆ្គងនានាដែលកើតមានឡើង។

ជាចុងបញ្ចប់នេះយើងខ្ញុំសូមថ្លែងអំណរគុណដល់ លោកអ្នកមានគុណ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ គ្រប់ជាន់ថ្នាក់ បងប្អូន និងមិត្តភក្តិទាំងអស់ ជួបប្រទះនូវប្រសិទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

អារម្ភកថា

បន្ទាប់ពីយើងខ្ញុំទាំងពីរនាក់ទទួលបានការអប់រំ បណ្តុះបណ្តាល យ៉ាងយកចិត្តទុកដាក់បំផុតពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទើបធ្វើឲ្យយើងខ្ញុំទទួលបាននូវចំណេះដឹងមួយដែលពោរពេញទៅដោយគុណភាព និងគុណតម្លៃ តាមរយៈការសិក្សាអស់រយៈពេលបួនឆ្នាំកន្លងមក ដែលអាចឲ្យយើងខ្ញុំយល់ដឹង និងស្គាល់យ៉ាងច្បាស់អំពីទ្រឹស្តីមួយមួយចំនួនធំ ដែលទាក់ទងជាមួយនឹងជំនាញគណនេយ្យ។ ជាការពិតណាស់សាកលវិទ្យាល័យបានផ្តល់ឱកាសឲ្យនិស្សិតធ្វើការសិក្សាស្រាវជ្រាវដើម្បីសរសេរសារណា ឬរបាយការណ៍កម្មសិក្សា ក្នុងការបញ្ចប់ការសិក្សារបស់ខ្លួន ព្រមទាំងបានធ្វើការផ្តល់នូវ ឱកាសឲ្យនិស្សិតយកទ្រឹស្តីដែលបានសិក្សាកន្លងមក ទៅអនុវត្តផ្ទាល់ក្នុងការងារជាក់ស្តែងនៅតាមស្ថាប័នផងដែរ។ របាយការណ៍ហិរញ្ញវត្ថុ គឺជារបាយការណ៍មួយដែលរៀបចំឡើងដើម្បីធ្វើការបង្ហាញព័ត៌មានអំពីប្រតិបត្តិការក្រុមហ៊ុន មានភាពរីកចម្រើនទៅមុខ ឬអន់ថយ។ របាយការណ៍ហិរញ្ញវត្ថុមានដូចជា តារាងតុល្យការ របាយការណ៍លទ្ធផល របាយការណ៍មូលធន/របាយការណ៍ប្រាក់ចំណេញរក្សាទុក និងរបាយការណ៍ចលនាលំហូរសាច់ប្រាក់។ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុពិតជាមាន សារៈសំខាន់ណាស់សម្រាប់អ្នកវិនិយោគ វាបានផ្តល់ព័ត៌មានឲ្យឃើញអំពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពអាជីវកម្ម មានដូចជា ចំណុចខ្លាំង និងចំណុចខ្សោយរបស់អង្គភាពអាជីវកម្មដែលវាដើរតួយ៉ាងសំខាន់ក្នុងការចូលរួម ការសម្រេចចិត្តរបស់អ្នកវិនិយោគ។ ម្យ៉ាងទៀត បច្ចុប្បន្ននេះយើងសង្កេតឃើញថាក្រុមហ៊ុនលក់រថយន្តម៉ាកល្បីមួយឈ្មោះ Tesla, Inc. គឺជាក្រុមហ៊ុនដែលមានភាពល្បីល្បាញទៅលើរថយន្តអគ្គិសនី ដែលកំពុងតែមានសន្ទុះនូវការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ប្រជាជនទូទាំងពិភពលោក ដែលទទួលស្គាល់លើផ្នែកគុណភាព បច្ចេកវិទ្យាទំនើប និងការអភិវឌ្ឍ ជាពិសេសការលើកកម្ពស់ការការពារបរិស្ថានព្រមទាំងកាត់បន្ថយការបំពុលបរិស្ថានដែលជាភាពលេចធ្លោរបស់ក្រុមហ៊ុនមួយនេះ។ ហេតុដូច្នេះហើយទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទដែលស្តីអំពី "ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Tesla, Inc." មកសិក្សាស្រាវជ្រាវ។

យើងខ្ញុំសង្ឃឹមថាសៀវភៅដែលយើងខ្ញុំបានចងក្រងឡើងនេះនឹងជាជំនួយដល់និស្សិត មិត្តអ្នកអាន និងអ្នកវិនិយោគទាំងអស់ទទួលបាននូវចំណេះដឹងបន្ថែមពីរបាយការណ៍ហិរញ្ញវត្ថុ និងបានស្វែងយល់បន្ថែមទៀតពីការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុក្នុងការយកមកវិភាគរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីជាប្រយោជន៍ក្នុងការសិក្សា ឬសម្រាប់ប្រើប្រាស់ផ្សេងៗ។ ទោះបីមានការខិតខំចងក្រងសៀវភៅយ៉ាងណា យើងខ្ញុំជឿជាក់ថា សៀវភៅពិតជាមានលក្ខណៈពុំទាន់ល្អឥតខ្ចោះនៅឡើយទេ ទាំងការប្រើប្រាស់ពាក្យពេចន៍ អក្ខរាវិរុទ្ធ និងខ្លឹមសារជាដើម។ យើងខ្ញុំរីករាយ និងស្វាគមន៍រាល់មតិយោបល់ដែលរិះគន់ និងកែលម្អក្នុងន័យស្ថាបនាពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់ពេលវេលាដោយក្តីសោមនស្សជាទីបំផុត។

មាតិការ

ទំព័រ

បញ្ជីអក្សរកាត់ iv

បញ្ជីតារាង v

បញ្ជីរូបភាព vi

បញ្ជីក្រាហ្វិច vii

សេចក្តីផ្តើម ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ១

សេចក្តីផ្តើម ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ១

៣. គោលបំណងនៃការស្រាវជ្រាវ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ២

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ២

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ៣

ជំពូកទី ១
រំលឹកទ្រឹស្តី

១.១. របាយការណ៍ហិរញ្ញវត្ថុ ៥

១.១.១. និយមន័យរបាយការណ៍ហិរញ្ញវត្ថុ ៥

១.១.២. សារៈសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ ៥

១.១.៣. បម្រើបម្រាស់ព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុ ៦

១.២. ទម្រង់នៃរបាយការណ៍ហិរញ្ញវត្ថុ ៧

១.២.១. របាយការណ៍លទ្ធផល ៨

១.២.២.របាយការណ៍មូលធនម្ចាស់/របាយការណ៍ប្រាក់ចំណេញរក្សាទុក ៩

១.២.៣.តារាងតុល្យការ ១០

១.២.៤.របាយការណ៍ចលនាលំហូរសាច់ប្រាក់ ១១

១.៣. ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ១២

១.៤. គោលបំណងនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ១២

១.៥. ឧបករណ៍ក្នុងការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ១៣

១.៥.១. ការវិភាគរបាយការណ៍ហិរញ្ញវត្ថុតាមជួរដេក ១៣

១.៥.២. ការវិភាគរបាយការណ៍ហិរញ្ញវត្ថុតាមជួរឈរ ១៤
១.៥.៣ ការវិភាគដោយប្រើប្រាស់រូបមន្តអនុបាត ១៤
១.៥.៣.១ អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលខ្លី ១៤
១.៥.៣.២ អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលវែង ១៦
១.៥.៣.៣ អនុបាតនៃលទ្ធភាពប្រើប្រាស់ទ្រព្យសកម្ម ១៨
១.៥.៣.៤ អនុបាតនៃលទ្ធភាពស្វែងរកប្រាក់ចំណេញ ២១
១.៥.៣.៥ អនុបាតទីផ្សារ ២៣

ជំពូកទី២

ស្ថានភាពទូទៅរបស់ក្រុមហ៊ុន Tesla, Inc.

២.១. ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន Tesla, Inc. ២៤
២.២. ប្រវត្តិសង្ខេបក្រុមហ៊ុន Tesla, Inc. ២៥
២.៣. និមិត្តិសញ្ញារបស់ក្រុមហ៊ុន Tesla និងការវិវត្តិន៍របស់និមិត្តិសញ្ញា ២៨
២.៣.១. ប្រវត្តិនិមិត្តិសញ្ញា ២៨
២.៣.២. ការវិវត្តិន៍របស់និមិត្តិសញ្ញា ២៨
២.៤. ប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន ៣០
២.៥. ផលិតផលនិងសេវាកម្មរបស់ Tesla ៣២
២.៦. យុទ្ធសាស្ត្រអាជីវកម្ម ៣៦
២.៧. យុទ្ធសាស្ត្រប្រកួតប្រជែងទូទៅរបស់ក្រុមហ៊ុន Tesla ៣៦
២.៨. អត្តប្រយោជន៍ក្នុងការប្រកួតប្រជែង ៣៧
២.៩. ការវិភាគទីផ្សារ ៣៧
២.១០. ដៃគូប្រកួតប្រជែងរបស់ក្រុមហ៊ុន Tesla ៣៨
២.១១. ដៃគូសហការរបស់ក្រុមហ៊ុន Tesla ៤០
២.១២. ចក្ខុវិស័យរបស់ក្រុមហ៊ុន Tesla ៤០
២.១៣. បេសកកម្មរបស់ក្រុមហ៊ុន Tesla ៤១
២.១៤. គុណតម្លៃសំខាន់របស់ក្រុមហ៊ុន Tesla ៤១

ជំពូកទី៣

ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Tesla, Inc.

៣.១. ការវិភាគតាមជួរដេក ៤៣
៣.១.១. ការវិភាគលើរបាយការណ៍លទ្ធផល ៤៣

៣.១.២. ការវិភាគលើតារាងតុល្យការ..... ៤៥
៣.២. ការវិភាគតាមផ្ទរឈរ..... ៤៧
៣.២.១. ការវិភាគលើរបាយការណ៍ចំណូលនិងចំណាយ..... ៤៧
៣.២.២. ការវិភាគលើតារាងតុល្យការ ៤៩
៣.៣. ការវិភាគលើអនុបាតរបស់ក្រុមហ៊ុន Tesla, Inc. ៥៣
៣.៣.១. ការវិភាគតាមរូបមន្តអនុបាតសន្ទនីយ៍ភាព (Liquidity Ratios)..... ៥៣
៣.៣.២. ការវិភាគតាមរូបមន្តអនុបាតផលិតភាពប្រាក់ចំណេញ (Profitability)..... ៥៦
៣.៣.៣. ការវិភាគតាមរូបមន្តអនុបាតសោធនភាព (Solvency Ratio) ៥៨

សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

សេចក្តីសន្និដ្ឋាន..... ៥៩
ការផ្តល់អនុសាសន៍..... ៦០

ឯកសារយោង

ឧបសម្ព័ន្ធ

បញ្ជីអក្សរកាត់

- IPO : Initial Public Offering

  " ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង "

- NASDAQ : National Associate of Securities Dealers Automated Quotation

  " សមាគមជាតិ របស់អ្នកជួញដូរមូលបត្រដោយប្រើប្រព័ន្ធស្វ័យប្រវត្តិ "

- SEC : Securities and Exchange Commission

  " គណៈកម្មការមូលបត្រ និងផ្សារមូលបត្រ "

បញ្ជីតារាង

តារាងទី១ ៖ ទម្រង់គំរូរបាយការណ៍លទ្ធផល ៨

តារាងទី២ ៖ ទម្រង់គំរូរបាយការណ៍មូលធនម្ចាស់ ៩

តារាងទី៣ ៖ ទម្រង់គំរូតារាតុល្យការ ១០

តារាងទី៤ ៖ ទម្រង់របាយការណ៍ចលនាលំហូរសាច់ប្រាក់ ១១

តារាងទី៥ ៖ តារាងគណនារបាយការណ៍លទ្ធផលតាមផ្ទួរដេករបស់ក្រុមហ៊ុន Tesla ៤៣

តារាងទី៦ ៖ តារាងគណនាតារាងតុល្យការតាមផ្ទួរដេករបស់ក្រុមហ៊ុន Tesla ៤៦

តារាងទី៧ ៖ តារាងគណនារបាយការណ៍លទ្ធផលតាមផ្ទួរឈររបស់ក្រុមហ៊ុន Tesla ៤៨

តារាងទី៨ ៖ តារាងគណនារបាយការណ៍តុល្យការតាមផ្ទួរឈររបស់ក្រុមហ៊ុន Tesla ៥០

តារាងទី៩ ៖ តារាងតម្លៃសុទ្ធរបស់អគារ រោងចក្រ និងសម្ភារៈ ៥១

តារាងទី១០ ៖ តារាងគណនាអនុបាតសន្ទនីយ៍ភាព របស់ក្រុមហ៊ុន Tesla ៥៣

តារាងទី១១ ៖ តារាងគណនាអនុបាតផលិតភាពប្រាក់ចំណេញរបស់ក្រុមហ៊ុន Tesla ៥៦

តារាងទី១២ ៖ តារាងគណនាអនុបាតសោធនភាពរបស់ក្រុមហ៊ុន Tesla, Inc. ៥៨

បញ្ជីរូបភាព

រូបភាពទី១ ៖ ទីស្នាក់ការកណ្តាលសាជីវកម្មរបស់ក្រុមហ៊ុន Tesla នៅ Gigafactory Texas ២៤

រូបភាពទី២ ៖ ទីស្នាក់ការកណ្តាលផ្នែកវិស្វកម្មសកលរបស់ក្រុមហ៊ុន Tesla នៅ Palo Alto ២៥

រូបភាពទី៣ ៖ និមិត្តសញ្ញារបស់ក្រុមហ៊ុន Tesla នៅចន្លោះឆ្នាំ ២០០៣ និង ២០១៧ ..... ២៩

រូបភាពទី៤ ៖ និមិត្តសញ្ញារបស់ក្រុមហ៊ុន Tesla ក្រោយការកែប្រែនៅ ឆ្នាំ២០១៧ ..... ២៩

រូបភាពទី៥ ៖ និមិត្តសញ្ញារបស់ក្រុមហ៊ុន Tesla ក្រោយការកែប្រែនៅ ឆ្នាំ២០១៧ ..... ២៩

រូបភាពទី៦ ៖ រថយន្តម៉ូដែល S ៣២

រូបភាពទី៧ ៖ រថយន្តម៉ូដែល X ៣២

រូបភាពទី៨ ៖ រថយន្តម៉ូដែល 3 ..... ៣៣

រូបភាពទី៩ ៖ រថយន្តម៉ូដែល Y ៣៣

រូបភាពទី១០ ៖ រថយន្តម៉ូដែល Tesla Sami ៣៣

រូបភាពទី១១ ៖ រថយន្តម៉ូដែល Cyber Truck ៣៣

រូបភាពទី១២ ៖ ស្ថានីយ៍ Tesla Supercharger នៅ Wittenberg ប្រទេសអាល្លឺម៉ង់ ៣៤

រូបភាពទី១៣ ៖ Destination Chargers ៣៤

រូបភាពទី១៤ ៖ Two Tesla Powerwall 2 home energy storage devices from Tesla Energy ... ៣៥

បញ្ជីក្រាហ្វិច

ក្រាហ្វិចទី១ ៖ ចំណូលសុទ្ធប្រចាំឆ្នាំរបស់ក្រុមហ៊ុន Tesla ៤៥

ក្រាហ្វិចទី២ ៖ អគារ រោងចក្រ និងសម្ភារៈរបស់ក្រុមហ៊ុន Tesla ក្នុងឆ្នាំ២០២២និង ២០២៣ ..... ៥២

ក្រាហ្វិចទី៣ ៖ អនុបាតចរន្ត, អនុបាតបង្វិលរហ័ស និងអនុបាតសាច់ប្រាក់របស់ក្រុមហ៊ុន Tesla, Inc. ពីឆ្នាំ ២០២១- ២០២៣..... ៥៤

ក្រាហ្វិចទី៤ ៖ ប្រៀបធៀបអនុបាតសន្ទនីយ៍ភាពរបស់ក្រុមហ៊ុនដែគួប្រកួតប្រជែងធំៗរបស់ក្រុមហ៊ុនTesla, Inc. ៥៥

ក្រាហ្វិចទី៥ ៖ អនុបាតចរន្ត, អនុបាតបង្វិលរហ័ស និងអនុបាតសាច់ប្រាក់របស់ក្រុមហ៊ុន Tesla, Inc.ពីឆ្នាំ ២០២១ - ២០២៣ ..... ៥៦

ក្រាហ្វិចទី៦ ៖ ប្រៀបធៀបអនុបាតផលិតភាពប្រាក់ចំណេញរបស់ក្រុមហ៊ុនដែគួប្រកួតប្រជែងធំៗរបស់ក្រុមហ៊ុន Tesla, Inc. ៥៨

សេចក្តីផ្តើម

សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ

យើងសង្កេតឃើញថា បច្ចុប្បន្ននេះពិភពលោកកំពុងជួបនូវបញ្ហាវិបត្តិមួយចំនួន ដែលធ្វើមានវិស័យមួយចំនួនបានធ្លាក់ចុះ ហើយក៏មានវិស័យមួយចំនួននៅតែរីកចម្រើន។ ហេតុដូចនេះហើយទើបបណ្តាលឲ្យចិត្តអ្នកវិនិយោគជាច្រើនធ្វើការវិនិយោគទៅ លើវិស័យផ្សេងៗគ្នា។ ក្នុងនោះផងដែរ បើយើងក្រឡេកមកមើលវិស័យសេដ្ឋកិច្ចឃើញថាកំពុងមានភាពជឿនលឿន គួរឲ្យកត់សម្គាល់។ ក្រុមហ៊ុនធំៗជាច្រើនបានពង្រីកសាខាអាជីវកម្មរបស់ខ្លួនសឹងតែគ្រប់ប្រទេសលើពិភពលោក។ ក្រុមហ៊ុនទាំងអស់នោះកំពុងធ្វើការយ៉ាងសកម្ម ដើម្បីឲ្យអាជីវកម្មរបស់ខ្លួនកាន់តែអាចលេចមុខលើទីផ្សារជាច្រើន និងហេតុផលមួយទៀតក៏ដើម្បីស្វែងរកអ្នកវិនិយោគទុន មកវិនិយោគលើក្រុមហ៊ុនខ្លួន។ ជាធម្មតា មុននឹងធ្វើការសម្រេចចិត្តវិនិយោគលើក្រុមហ៊ុនណាមួយ អ្នកវិនិយោគសុទ្ធត្រូវដឹងអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះជាមុនសិន ដោយធ្វើការពិនិត្យទៅលើរបាយការណ៍ហិរញ្ញវត្ថុយ៉ាងហ្មត់ចត់ជាទីបំផុត ដើម្បីជៀសវាងនូវការជួបវិបត្តិមួយចំនួន ក៏ដូចជាហានិភ័យផ្សេងៗផងដែរ។

របាយការណ៍ហិរញ្ញវត្ថុមានសារៈសំខាន់ណាស់សម្រាប់អោយក្រុមហ៊ុនបង្ហាញទៅដល់អ្នកវិនិយោគ ព្រោះថាការរៀបចំ របាយការណ៍ហិរញ្ញវត្ថុបានត្រឹមត្រូវ ការអនុវត្ត និងលទ្ធផលរបស់ក្រុមហ៊ុនដែលទទួលបានជាសញ្ញាបង្ហាញពីដំណើរការរបស់ក្រុមហ៊ុន ជាពិសេសព័ត៌មានហិរញ្ញវត្ថុដែលទទួលបានពីការវិភាគរបាយការណ៍ហិរញ្ញវត្ថុនេះមានអត្ថប្រយោជន៍ខ្លាំងណាស់ចំពោះអ្នកវិនិយោគ ក៏ដូចជាម្ចាស់ក្រុមហ៊ុនផ្ទាល់ ដើម្បីយកជាជំនួយក្នុងការសម្រេចចិត្តក្នុងការវិនិយោគឲ្យកាន់តែមានប្រសិទ្ធភាព។ យោងទៅតាមការបង្ហាញខាងលើយើងអាចនិយាយបានថា របាយការណ៍ហិរញ្ញវត្ថុត្រូវតែរៀបចំឡើងប្រកបដោយភាពសុក្រឹត្យ និងហ្មត់ចត់បំផុត ពីព្រោះវាជាប់ពាក់ព័ន្ធទៅនឹងការព្យាករណ៍ ការសម្រេចចិត្ត និង ការរំពឹងទុករបស់អ្នកវិនិយោគដែលចូលរួមក្នុងដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន។

ដោយហេតុតែការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនអាចធ្វេសប្រហែសបាន និងជាកម្លាំងចលករជួយឱ្យក្រុមហ៊ុនទទួលបានផលចំណេញ និងភាពជោគជ័យទៀតនោះ ទើបក្រុមយើងខ្ញុំចង់សិក្សាស្វែងយល់ឱ្យបានកាន់តែស៊ីជម្រៅថែមទៀតនូវការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុតាមរយៈការលើកយកប្រធានបទ " ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Tesla, Inc." មកធ្វើការបង្ហាញ។

២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសារតែក្រុមហ៊ុន Tesla, Inc. ជាក្រុមហ៊ុនដ៏ល្បីមួយដែលផលិត សេវាកម្ម និង លក់រថយន្តឈានមុខគេ ជាពិសេសរថយន្តអគ្គិសនី ហើយត្រូវបានទទួលស្គាល់ថា ជាក្រុមហ៊ុនដែលមានការអភិវឌ្ឍន៍លឿនខាងបច្ចេកវិទ្យា និងការលើកកម្ពស់ការការពារបរិស្ថានព្រមទាំងកាត់បន្ថយការបំពុលបរិស្ថាន ទើបក្រុមហ៊ុនទទួលបានការគាំទ្រយ៉ាងច្រើនពីសំណាក់ប្រជាជនទូទាំងពិភពលោក ។ ហេតុយ៉ាងដូច្នេះហើយ យើងនឹងធ្វើការសិក្សា

ថា តើស្ថានភាពទូទៅនិងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនTesla, Inc. មានស្ថានភាពបែបណាដែរ? ហើយប្រសិនបើប្រៀបធៀបជាមួយក្រុមហ៊ុនដែលជាដៃគូប្រកួតប្រជែង មានលក្ខណៈដូចម្តេចដែរ ?

៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Tesla, Inc. គឺដើម្បីសិក្សាស្វែងយល់ឲ្យកាន់តែស៊ីជម្រៅក្នុងការបង្កើនចំណេះដឹងបន្ថែម និងបទពិសោធន៍ជាច្រើនទៀត។ ការសិក្សាពីការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Tesla, Inc. នេះផ្តោតសំខាន់ទៅលើ ៖

- សិក្សាអំពីវិធីសាស្ត្រក្នុងការវិភាគរបាយការណ៍ហិរញ្ញវត្ថុ
- សិក្សាអំពីស្ថានភាពទូទៅរបស់ក្រុមហ៊ុន Tesla, Inc.
- សិក្សាអំពីលទ្ធផលនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Tesla, Inc.
- សម្រាប់បំពេញលក្ខខណ្ឌកំណត់សម្រាប់ថ្នាក់បរិញ្ញាបត្រដែលតម្រូវដោយសាកលវិទ្យាល័យ។

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Tesla, Inc. នេះគឺ ផ្តោតសំខាន់ទៅលើតែស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដើម្បីស្វែងយល់ពីលទ្ធភាពទូទាត់បំណុល លទ្ធភាពស្វែងរកប្រាក់ចំណេញ ដោយពុំបានធ្វើការបកស្រាយលំអិតគ្រប់ជ្រុងជ្រុយឡើយ។ ម្យ៉ាងវិញទៀត ដោយសារតែពេលវេលាមានកំណត់ ការសិក្សានេះគឺសិក្សាតែទៅលើរបាយការណ៍លទ្ធផល និងតារាងតុល្យការតែប៉ុណ្ណោះ។ ចំពោះទិន្នន័យដែលត្រូវបានយកមកបង្ហាញក្នុងរបាយការណ៍ស្រាវជ្រាវនេះ ត្រូវបានដកស្រង់ចេញពីរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Tesla, Inc. ចាប់ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៣ ពោលគឺ ៣ ឆ្នាំចុងក្រោយ។

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានផ្តល់នៅអត្ថប្រយោជន៍ដល់ និស្សិត អ្នកស្រាវជ្រាវ និងសាធារណជនទាំងអស់ដូចជា ៖

- យល់ដឹងពីស្ថានភាពហិរញ្ញវត្ថុ និង ការគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយ ឱ្យបានច្បាស់លាស់ វាបានជួយដល់ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន អាចធ្វើការសម្រេចចិត្ត ក្នុងការប្រកបអាជីវកម្មរបស់ខ្លួនបានត្រឹមត្រូវ
- ជួយដល់អ្នកវិនិយោគ ក៏ដូចជាសាធារណជនទូទៅឲ្យដឹងពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន
- ទុកជាឯកសារសម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗ។

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Tesla, Inc. សម្រេច ជោគជ័យទៅបាន ដោយសារយើងខ្ញុំទាំងពីរនាក់ បានប្រើប្រាស់ទិន្នន័យដែលបានមកពីសៀវភៅ និងឯកសារផ្សេងៗដូចជា ៖

- ✓ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំពីឆ្នាំ ២០២១ ដល់ ឆ្នាំ២០២៣ ពីគេហទំព័រជាផ្លូវការរបស់ក្រុមហ៊ុន Tesla, Inc.
- ✓ សៀវភៅនានាដែលមាននៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលពាក់ព័ន្ធការវិភាគរបាយការណ៍ហិរញ្ញវត្ថុ
- ✓ ឯកសារដែលបានមកពីគេហទំព័រផ្លូវការ និង គេហទំព័រផ្សេងៗដែលអាចទុកចិត្តបាន ដែលមាននៅលើបណ្តាញអ៊ីនធើណែត ដែលពាក់ព័ន្ធនឹង Tesla

ជារួម យើងខ្ញុំប្រើប្រាស់ទិន្នន័យបន្ទាប់បន្សំ(secondary data)សម្រាប់ធ្វើការស្រាវជ្រាវនេះ។

ការវិភាគទិន្នន័យ ៖ នៅក្នុងការវិភាគទិន្នន័យរបស់ក្រុមហ៊ុន Tesla, Inc. យើងនឹងប្រើប្រាស់នូវវិធីសាស្ត្រពីរបែបគឺ វិធីសាស្ត្របែបបរិមាណវិស័យ (Quantitative Method) និងវិធីសាស្ត្របែបគុណវិស័យ (Qualitative Method) ដើម្បីធ្វើការបកស្រាយនិងវិភាគលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Tesla, Inc.។ ឧបករណ៍ចំនួនបីដែលយើងនឹងយកមកប្រើប្រាស់ក្នុងការវិភាគទិន្នន័យនោះមាន ការវិភាគតាមជួរដេក (Horizontal analysis) ការវិភាគតាមជួរឈរ (Vertical analysis) និងការវិភាគតាមអនុបាត (Ratios analysis)។

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឲ្យការស្រាវជ្រាវមួយនេះកាន់តែមានភាពងាយស្រួល តាមលំដាប់លំដោយ និងមានគោលការណ៍ច្បាស់លាស់ គឺត្រូវតែបែងចែកជាបី ជំពូកដោយអមមកជាមួយសេចក្តីផ្តើម ព្រមទាំងសេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ ដូចបង្ហាញខាងក្រោមនេះ ៖

- ➢ សេចក្តីផ្តើម ៖ ក្នុងនោះរួមមាន លំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ។
- ➢ ជំពូកទី ១ ៖ រំលឹកទ្រឹស្តី ក្នុងនោះរួមមានបង្ហាញពីអ្វីទៅជា របាយការណ៍ហិរញ្ញវត្ថុ ទម្រង់នៃរបាយការណ៍ហិរញ្ញវត្ថុ និង ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ។
- ➢ ជំពូកទី ២ ៖ ស្ថានភាពទូទៅរបស់ក្រុមហ៊ុន Tesla, Inc. បង្ហាញពីព័ត៌មានទូទៅរបស់ក្រុមហ៊ុន ប្រវត្តិអាជីវកម្មរបស់ក្រុមហ៊ុន ព្រមទាំងផលិតផលរបស់ក្រុមហ៊ុន Tesla, Inc.
- ➢ ជំពូកទី ៣ ៖ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Tesla, Inc.
    - ការវិភាគតាមជួរដេក និងជួរឈរ

- ការវិភាគតាមអនុបាត
- លទ្ធផលនៃការវិភាគ

➢ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

- សេចក្តីសន្និដ្ឋាន
- ការផ្តល់អនុសាសន៍

រចនាសម្ព័ន្ធនៃការស្រាវជ្រាវ



ជំពូកទី១

រំលឹកគ្រឹស្ត

ជំពូកទី១

រំលឹកទ្រឹស្តី

១.១. របាយការណ៍ហិរញ្ញវត្ថុ

១.១.១.និយមន័យរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ គឺជារបាយការណ៍មួយប្រភេទ ដែលរៀបចំឡើងផ្អែកទៅតាមវិធីសាស្ត្រ គណនេយ្យ ដើម្បីបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយនៅពេលកំណត់ជាក់លាក់។ របាយការណ៍ហិរញ្ញវត្ថុត្រូវ បានគេកំណត់ន័យដូចខាងក្រោម ៖

• របាយការហិរញ្ញវត្ថុ គឺជារបាយការណ៍ ដែលរៀបចំឡើងផ្អែកលើវិធីសាស្ត្រគណនេយ្យ មានន័យថា ការរៀបចំ របាយការណ៍ហិរញ្ញវត្ថុពឹងផ្អែកទាំងស្រុងទៅលើការកត់ត្រាទិន្នន័យរបស់គណនេយ្យនៅក្នុងបណ្ណាសៀវភៅផ្សេងៗ

• របាយការណ៍ហិរញ្ញវត្ថុឆ្លុះបញ្ចាំង ពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយដូចជា ចំណូល ចំណាយ ទ្រព្យ សកម្ម និង លំហូរសាច់ប្រាក់ចូល ឬ ចេញ។ ដូច្នេះយើងអាចដឹងពីចំណុចខ្លាំង និងចំណុចខ្សោយ និងសក្តានុ ពលរបស់ក្រុមហ៊ុនតាមរយៈរបាយការណ៍ហិរញ្ញវត្ថុរបស់វា។

• របាយការណ៍ហិរញ្ញវត្ថុរៀបចំឡើងនៅពេលវេលាមួយកំណត់ជាក់លាក់ ៖ ជាទូទៅរបាយការណ៍ហិរញ្ញវត្ថុ ត្រូវ បានគេរៀបចំឡើងនៅចំណុចពេលវេលាមួយកំណត់ជាក់លាក់ដូចជានៅថ្ងៃទី៣១ ខែមីនា ឬ ថ្ងៃទី៣១ ខែធ្នូ ជា ដើម។[1]

១.១.២.សារៈសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ

អត្ថប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុមានដូចជា ៖

• **ជួយក្នុងការវាស់ស្វង់ផលចំណេញ** ៖ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុជួយឱ្យដឹងថាតើដំណើរការអាជីវកម្ម កំពុងបង្កើតប្រាក់ចំណេញ ឬ ខាត។ វាក៏ជួយឲ្យដឹងផងដែរថាតើប្រាក់ចំណេញ ឬ ខាត របស់ក្រុមហ៊ុនកំពុងកើន ឡើង ឬ ថយចុះ បន្ថែមពីនេះវាជួយឲ្យយើងដឹងពីសមត្ថភាពអាជីវកម្មក្នុង ការបង់ការប្រាក់ទៅលើកម្ចីមូលធន និងសមត្ថភាពទូទាត់ភាគលាភដល់ភាគហ៊ុននិករបស់ខ្លួន។

• **ជួយក្នុងការវាស់វែងពីភាពរឹងមាំនៃហិរញ្ញវត្ថុ** ៖ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុជួយឱ្យយើងយល់ពី ភាពខ្លាំង នៃហិរញ្ញវត្ថុរួមរបស់អាជីវកម្ម។ វាក៏ជួយក្នុងការសម្រេចចិត្តទាក់ទងនឹងមូលនិធិដែលមានស្រាប់សម្រាប់ការទិញ ទ្រព្យសកម្ម ទូទាត់បំណុលជាដើម។ វាក៏ជួយឲ្យដឹងថាតើប្រភពមូលនិធិរបស់ក្រុមហ៊ុន (ប្រាក់ចំណូលរក្សា ទុកក្នុងឆ្នាំកន្លងមក) មានគ្រប់គ្រាន់ឬត្រូវការប្រាក់កម្ចីបន្ថែម ទៀតពីប្រភពខាងក្រៅ។

[1] ប្រភព October 5, 2016 – khemsarith (wordpress.com) (ចូលទស្សនាថ្ងៃ១៥ មេសា ២០២៤)

- **ជួយឱ្យដឹងពីប្រសិទ្ធភាពនៃការគ្រប់គ្រង** ៖ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុជួយឱ្យដឹងពីប្រសិទ្ធភាពនៃការគ្រប់គ្រងក្នុងការដំណើរការអាជីវកម្ម។ វាជួយឲ្យដឹងថាតើគោលការណ៍ហិរញ្ញវត្ថុដែលអនុវត្តន៍តាមការគ្រប់គ្រងត្រឹមត្រូវឬអត់។ [2]

១.១.៣. បម្រើបម្រាស់ព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុ

ព័ត៌មានហិរញ្ញវត្ថុត្រូវបានយកទៅប្រើប្រាស់ក្នុងគោលដៅខុសៗគ្នា អាស្រ័យទៅតាមការអនុវត្តប្រតិបត្តិការអាជីវកម្មនិងព្រឹត្តិការណ៍ផ្សេងៗ ដែលមានឥទ្ធិពលទៅលើអង្គភាពអាជីវកម្មទាំងមូល។ អ្នកគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុទាំងអស់តែងតែយកចិត្តទុកដាក់ និងធ្វើការតាមដានចំពោះស្ថានភាពហិរញ្ញវត្ថុអង្គភាពអាជីវកម្ម របស់ខ្លួនទាំងនៅពេលបច្ចុប្បន្ន និងនាពេលអនាគត។ ជាទូទៅអ្នកប្រើប្រាស់ ព័ត៌មានហិរញ្ញវត្ថុត្រូវបានបែងចែកជាពីរគឺ អ្នកប្រើប្រាស់ផ្ទៃក្នុង(Internal Usher) និងអ្នកប្រើប្រាស់ខាងក្រៅ (External Usher)។

- ការប្រើប្រាស់ផ្ទៃក្នុង

អ្នកប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុ គឺជាបុគ្គលដែលចូលរួមក្នុងការគ្រប់គ្រងប្រតិបត្តិការរបស់អាជីវកម្មដូចជាអ្នកគ្រប់គ្រង អ្នកប្រឹក្សាយោបល់ សវនករផ្ទៃក្នុង អ្នកគ្រប់គ្រងកញ្ចប់ថវិការ និងអ្នកស្រាវជ្រាវអភិវឌ្ឍន៍ជាដើម។ ជាក់ស្តែង ចំពោះអ្នកគ្រប់គ្រងត្រូវបានប្រើប្រាស់វាក្នុងការវាយតម្លៃ និងទូទាត់សងតាមមូលដ្ឋាននៃគោលការណ៍គណនេយ្យដូចជាប្រាក់ចំណេញ និងប្រាក់ចំណេញសុទ្ធ។ ក្នុងនោះផងដែរសារៈសំខាន់ក្នុងការប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុផ្ទៃក្នុងមួយទៀតគឺ សម្រាប់ងាយស្រួលរៀបចំផែនការអាជីវកម្មនាពេលអនាគត និង សម្រាប់ពិនិត្យមើល ភាពប្រាកដនិយម (Realism) នៃការសន្ទតដែលបានធ្វើនៅក្នុងគម្រោងនោះ។

- ការប្រើប្រាស់ខាងក្រៅ

របាយការណ៍ហិរញ្ញវត្ថុក៏ត្រូវបានយកទៅប្រើប្រាស់ដោយភាគីនៅក្រៅក្រុមហ៊ុន ដែលរួមមានដូចជាម្ចាស់ឥណទានរយៈខ្លី និងរយៈពេលវែង អ្នកវិនិយោគទុន អ្នកផ្គត់ផ្គង់ ដៃគូរប្រកួតប្រជែង អតិថិជន ភ្នាក់ងារពន្ធដារ និងអ្នកដែលជាប់ពាក់ព័ន្ធផ្សេងៗទៀតជាដើម ហើយព័ត៌មានហិរញ្ញវត្ថុត្រូវបានពួកគេយកទៅប្រើប្រាស់ក្នុងគោលបំណងមួយចំនួនដូចខាងក្រោម ៖

> ម្ចាស់ឥណទាន ៖ ប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុដើម្បីវិភាគទៅលើដំណើរការអាជីវកម្ម និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនពេលសម្រេចចិត្តផ្តល់ ឬ បដិសេធមិនផ្តល់ឥណទាន និងដើម្បីចង់ដឹងពីលទ្ធភាពសងបំណុលរបស់ក្រុមហ៊ុន។

[2] ប្រភព October 5, 2016 – khemsarith (wordpress.com) (ចូលទស្សនាថ្ងៃ១៥ មេសា ២០២៤)

> អ្នកវិនិយោគ ៖ ត្រូវការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុដើម្បីថ្លឹងថ្លែងពីដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន មុនពេលសម្រេចចិត្តវិនិយោគ ឬ បន្តវិនិយោគបន្តទៅទៀត។

> អ្នកផ្គត់ផ្គង់ ៖ ពួកគេប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុស្រដៀងទៅនឹងម្ចាស់ឥណទានដែរ អ្នកផ្គត់ផ្គង់ត្រូវការព័ត៌មានហិរញ្ញវត្ថុមុនពេលសម្រេចចិត្តផ្គត់ផ្គង់ដោយជំពាក់ឱ្យក្រុមហ៊ុន។

> ដៃគូរប្រកួតប្រជែង ៖ ដៃគូប្រកួតប្រជែងប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុដើម្បីចង់ដឹងស្ថានភាពហិរញ្ញវត្ថុ និង ចង់ដឹងពីភាពខ្លាំងនៃរបាយការណ៍របស់ក្រុមហ៊ុនបើពួកគេអាច។

> អតិថិជន ៖ អតិថិជនធំៗប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តវាយតម្លៃពីប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន ដើម្បីកំណត់នូវជំនឿទុកចិត្តរបស់ខ្លួនមកលើក្រុមហ៊ុននាពេលអនាគត។

> ភ្នាក់ងារពន្ធដារ ៖ ធ្វើការត្រួតពិនិត្យទៅលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងគោលបំណងកំណត់ទំហំទឹកប្រាក់ក្នុងការបង់ពន្ធជាដើម។

> រាជរដ្ឋាភិបាល ៖ គោលបំណងក្នុងព័ត៌មានហិរញ្ញវត្ថុ គឺដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យពីសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនងាយស្រួលក្នុងការដឹងពីស្ថានភាពរួមនៃសេដ្ឋកិច្ចជាតិទាំងមូល។[3]

១.២.ទម្រង់របាយការណ៍ហិរញ្ញវត្ថុ

ជាទូទៅ របាយការណ៍ហិរញ្ញវត្ថុមានបួនធំៗគឺ ៖

- របាយការលទ្ធផល (Income Statement)
- របាយការណ៍មូលធនម្ចាស់/របាយការណ៍ប្រាក់ចំណេញរក្សាទុក (Statement of Retained Earnings)
- តារាងតុល្យការ (Balance Sheet)
- របាយការណ៍ចលនាលំហូរសាច់ប្រាក់ (Statement of Cash Flow)

១.២.១.របាយការណ៍លទ្ធផល (Income Statement)

❖ និយមន័យ

របាយការណ៍លទ្ធផល គឺជារបាយការណ៍ហិរញ្ញវត្ថុសំខាន់មួយក្នុងចំណោមរបាយការណ៍ហិរញ្ញវត្ថុ សំខាន់ៗបួន ដែលផ្តល់នូវគណនេយ្យលម្អិតនៃប្រាក់ចំណូលដែលទទួលបាន និងចំណាយដែលបានបង់ក្នុង កំឡុងពេលគណនេយ្យជាក់លាក់មួយ។ ជាទូទៅវារាយការណ៍ពីភាពជោគជ័យ ឬ បរាជ័យផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងជាឧបករណ៍ដ៏មានតម្លៃសម្រាប់អ្នកគ្រប់គ្រងផ្តោតជាចម្បងលើការកែលម្អប្រាក់ចំណេញ និងការបង្កើន

[3] ប្រភព Ross Westerfield Jordan., Fundamentals Of Corporate Finance (បោះពុមលើកទី៨, ទំព័រទី ៧១)

លំហូរសាច់ប្រាក់។ របាយការណ៍ប្រាក់ចំណូលទូទៅផ្តល់នូវទស្សនៈហិរញ្ញវត្ថុមិនមែនជាប្រតិបត្តិការទេ។ ដូច្នេះ ហើយ ក្នុងនាមជាអ្នកដឹកនាំអាជីវកម្មដែលទទួលខុសត្រូវក្នុងការរីកចម្រើនរបស់អាជីវកម្មត្រូវមានសមត្ថភាពមើលដឹងអំពីប្រភពដើមនៃចំណូលនិងចំណាយរបស់ក្រុមហ៊ុនឲ្យបានត្រឹមត្រូវ។[4]

តារាងទី១ ៖ ទម្រង់គំរូបាយការណ៍លទ្ធផល

Company Name
Income Statement
For the year Ended December, 31, 20XX

Sale Revenue		xxx
Cost of goods sold		(xxx)
Gross Profit		xxx
Operating Expense		
Research And Development expense	xxx	
Selling and Administration expense	xxx	
Total operating expense		xxx
Operating Income		xxx
Other Income		(xxx)
Other Expense		(xxx)
Income before income tax		xxx
Income Tax expense		(xxx)
Net income		**xxx**
Earnings per share of common stock		xxx

១.២.២.របាយការណ៍មូលធនម្ចាស់/របាយការណ៍ប្រាក់ចំណេញរក្សាទុក (Statement Retained Earnings)

❖ និយមន័យ

របាយការណ៍ប្រាក់ចំណេញរក្សាទុក គឺជារបាយការណ៍ហិរញ្ញវត្ថុដែលសង្ខេបពីការផ្លាស់ប្តូរប្រាក់ចំណេញបានរក្សាទុកក្នុងកំឡុងពេលជាក់លាក់ណាមួយ ឬជាចំណែកនៃប្រាក់ចំណូលសុទ្ធដែលនៅសល់បន្ទាប់ពីការបែងចែកភាគលាភទៅឱ្យម្ចាស់ភាគហ៊ុន ប៉ុន្តែបានរក្សាទុកក្នុងអាជីវកម្មសម្រាប់គោលបំណងផ្សេងៗ ដូចជាការពង្រីកអាជីវកម្មបន្ថែមនាពេលអនាគត ឬ សម្រាប់បំពេញកាតព្វកិច្ចបំណុលរបស់ក្រុមហ៊ុនជាដើម។

[4] ប្រភព Why You Should Use an Operational Income Statement for Analytics and Planning - 3C Software (ចូលទស្សនាថ្ងៃ១៥ មេសា ២០២៤)

ជាទូទៅប្រាក់ចំណេញរក្សាទុកកើនឡើងនៅពេលប្រាក់ចំណេញកើនឡើង ឬនៅពេលក្រុមហ៊ុនបានធ្វើការបែងចែកភាគលាភតិចទៅឱ្យម្ចាស់ភាគហ៊ុន។ ហើយវាថយចុះនៅពេល ដែលប្រាក់ចំណូលរបស់ក្រុមហ៊ុនថយចុះ ឬក្រុមហ៊ុនធ្វើការបែងចែកភាគលាភទៅឱ្យម្ចាស់ភាគហ៊ុនច្រើន។[5]

តារាងទី២ ៖ ទម្រង់គំរូបាយការណ៍មូលធនម្ចាស់

Company Name	
Statement of stock holder's Equity	
For the year ended Dec 31, 20XX	
Retained Earnings at beginning of the period	xxx
Add: Net Income current year	xxx
Less: Dividend	(xxx)
Retained Earnings at the end of the period	xxx

១.២.៣.តារាងតុល្យការ (Balance Sheet)

❖ និយមន័យ

តារាងតុល្យការគឺបង្ហាញនូវស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយក្នុងការិយបរិច្ឆេទគណនេយ្យ។ ការិយបរិច្ឆេទគណនេយ្យជាទូទៅ គឺមានរយៈពេលមួយឆ្នាំ(១២ខែ) មួយឆមាស (៦ខែ) ឬ មួយត្រីមាស(៣ខែ)។ តារាងតុល្យការ គឺជាតារាងមួយដែលបានរាយការណ៍ព័ត៌មានស្តីពី ទ្រព្យសកម្ម(Asset) បំណុល (Liabilities) និងទ្រព្យម្ចាស់ (Equity) របស់អង្គភាពអាជីវកម្មមួយក្នុងកំឡុងពេលដ៏ជាក់លាក់។ តារាងតុល្យការបានបង្ហាញពីផ្នែកទ្រព្យសកម្ម បំណុល និងមូលធនទ្រព្យម្ចាស់ដែលមានតុល្យភាពនឹងគ្នា។ ហើយផ្នែកទ្រព្យវាបានបង្ហាញពីការប្រើប្រាស់មូលនិធិដើម្បីបម្រើនូវប្រតិបត្តិការរបស់ខ្លួន។ ចំណែកឯផ្នែកបំណុលវាបានបង្ហាញពីប្រភពផ្សេងៗនៃប្រតិបត្តិការ។[6]

[5] ប្រភព Statement of retained earnings - explanation, format, example, formula | Accounting For Management (ចូលទស្សនាថ្ងៃ១៥ មេសា ២០២៤)

[6] ប្រភព Ross Westerfield Jordan., Fundamentals Of Corporate Finance (បោះពុមលើកទី ៨, ទំព័រទី ២២) ចូលទស្សនាថ្ងៃ ១៥ មេសា ២០២៤

សមីការតារាងតុល្យការមានធាតុដែលចូលរួមសំខាន់ៗបីគឺ៖

ទ្រព្យសកម្ម = បំណុល + ទ្រព្យម្ចាស់

Asset = Liabilities + Equity

តារាងទី៣៖ ទម្រង់គំរូតារាតុល្យការ

Company Name

Balance Sheet

As of December, 20XX

Current Assets			
Cash		xxx	
Marketable Securities		xxx	
Accounts Receivable		xxx	
Inventories		xxx	
Prepaid Expense		xxx	
Total Current assets			xxx
Property, Plant, and, Equipment			
Land			
Building and Equipment	xxx		
Less Accumulated Depreciation	(xxx)		
Net Property, Plant, and Equipment		xxx	
Total property, plant and Equipment			xxx
Other Assets			
Investments		xxx	
Intangible Assets		xxx	
Total assets			xxx
Current Liabilities			
Accounts Payable		xxx	
Salaries Payable		xxx	
Taxes Payable		xxx	
Accrued Expense		xxx	
Deferred Revenue		xxx	
Total Current Liabilities			xxx
Non-current liabilities			
Long term debt			xxx
Total liabilities			xxx
Shareholder's Equity			
Retained earning		xxx	
Total Shareholder's equity			xxx
Total Liabilities and Shareholder's equity			xxx

១.២.៤.របាយការណ៍ចលនាលំហូរសាច់ប្រាក់ (Statement of Cash Flows)

❖ និយមន័យ

របាយការណ៍នេះ បកស្រាយរាល់ការប្រែប្រួលស្តីពីស្ថានភាពហិរញ្ញវត្ថុគ្រប់សកម្មភាពទាំងលំហូរសាច់ប្រាក់ចេញ និងលំហូរសាច់ប្រាក់ចូល នៅក្នុងការិយបរិច្ឆេទជាក់លាក់មួយ។ សកម្មភាពបី ដែលមានឥទ្ធិពល ទៅលើរបាយការណ៍លំហូរសាច់ប្រាក់គឺសកម្មភាពប្រតិបត្តិការ (Operating Activities) សកម្មភាពវិនិយោគ (Investing Activities) និងសកម្មភាពហិរញ្ញប្បទាន (Financing Activities)។ សកម្មភាពប្រតិបត្តិការមានពាក់ព័ន្ធទៅនឹងសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន រីឯសកម្មភាពវិនិយោគទាក់ទងទៅនឹងការទិញ និងការលក់មូលបត្រ ឬ ទ្រព្យសម្បត្តិ និងសកម្មភាពហិរញ្ញប្បទានគឺវាមានការពាក់ព័ន្ធទៅនឹងការវិនិយោគរបស់ម្ចាស់អាជីវកម្ម។[7]

តារាងទី៤ ៖ ទម្រង់របាយការណ៍ចលនាលំហូរសាច់ប្រាក់

Company Name Statement of Cash Flows For the year end December 31, 20XX	
Net income	xxx
Cash Flows from Operation Activities	
Add: depreciation expense	xxx
Increase in accounts receivable	xxx
Decrease in inventory	xxx
Decrease in accounts payable	xxx
Cash provided (Used) in operating activities	xxx
Cash Flows from Investing Activities	
Capital Expenditures	xxx
Proceeds from sale of property	xxx
Cash provided (used) in investing activities	xxx
Cash Flows from Financing Activities	
Borrowing of long-term debt	xxx
Cash dividends	xxx
Purchase of treasury stocks	xxx
Cash provided (used) in Financing activities	xxx
Net increase in Cash	xxx
Cash at the beginning of the year	xxx
Cash at the end of the year	xxx

[7] ប្រភព អ្វីទៅជារបាយការណ៍លំហូរសាច់ប្រាក់ ? (khsearch.com) ចូលទស្សនាថ្ងៃ១៥ មេសា ២០២៤

១.៣.ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ រួមមានការប្រើប្រាស់ឧបករណ៍វិភាគ និងបច្ចេកទេសនៃការវិភាគ របាយការណ៍ហិរញ្ញវត្ថុនោះ ក៏ដូចជាបណ្តាទិន្នន័យទំនាក់ទំនងផ្សេងៗទៀតដើម្បីទទួលបាននូវព័ត៌មានសំខាន់ៗ។ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ គឺជាការត្រួតពិនិត្យទៅលើផ្នែកផ្សេងៗនៃរបាយការណ៍ហិរញ្ញវត្ថុដែលផ្នែកទាំងនោះមានទំនាក់ទំនងគ្នាទៅវិញទៅមក និងឆ្លុះបញ្ចាំងពីទិដ្ឋភាពរបស់អង្គភាពទាំងមូល។ ដើម្បីវិភាគរបាយការណ៍ហិរញ្ញវត្ថុយើងត្រូវវិភាគទៅលើគោលបំណងទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុ ហើយវិភាគថាវាមានទំនាក់ទំនងយ៉ាងដូចម្តេចខ្លះជាមួយនិងទិន្នន័យសម្រាប់ការសម្រេចចិត្តរបស់អាជីវកម្មទាំងមូល។[8]

១.៤.គោលបំណងនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ គឺដើម្បីចង់ដឹងពីស្ថានភាពនៃដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនពី អតីតកាល បច្ចុប្បន្ន និងអនាគត ព្រមទាំងនូវផ្តល់ភាពងាយស្រួលដល់អ្នកខាងក្នុងនិងអ្នកខាងក្រៅក្រុមហ៊ុន ដើម្បីកំណត់ភាពខ្លាំង និងភាពខ្សោយរបស់អង្គភាព។

គោលបំណងសំខាន់ៗនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម ៖

- ❖ ការវាយតម្លៃពីការអនុវត្តក្នុងអតីតកាល(Assessment of Past Performance): ប្រតិបត្តិការនៅក្នុង អតីតកាលគឺជាសូចនាករដ៏ល្អមួយនៃការអនុវត្តនាពេលអនាគត។ វិនិយោគិន ឬម្ចាស់បំណុលចាប់អារម្មណ៍នឹងនិន្នាការនៃការលក់ ចំណាយថ្លៃដើម ចំណាយប្រតិបត្តិការ ប្រាក់ចំណេញសុទ្ធ លំហូរសាច់ប្រាក់ និងធនភាគលាភ និងការវិនិយោគកាលពីអតីតកាល។ និន្នាការទាំងនេះផ្តល់ជូននូវ មធ្យោបាយ សម្រាប់វិនិច្ឆ័យការគ្រប់គ្រងប្រតិបត្តិការអាជីវកម្មពីអតីតកាល និងជាសូចនាករ ដែលអាចធ្វើទៅបាននៃការអនុវត្តនាពេលអនាគត។
- ❖ ការវាយតម្លៃពីស្ថានភាពបច្ចុប្បន្ន(Assessment of current position): ការវិភាគរបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីស្ថានភាពបច្ចុប្បន្នរបស់ក្រុមហ៊ុនទាក់ទងទៅ នឹងប្រភេទទ្រព្យសកម្មដែលគ្រប់គ្រងដោយក្រុមហ៊ុនឬអាជីវកម្មមួយ និងបំណុលផ្សេងៗដែលក្រុមហ៊ុនត្រូវសងគេ។
- ❖ ការព្យាករណ៍ពីភាពចំណេញនិងការរីកចម្រើន (Prediction of Profitability and Growth prospects): ការវិភាគរបាយការណ៍ហិរញ្ញវត្ថុជួយក្នុងការវាយតម្លៃ និងព្យាករណ៍អំពីលទ្ធភាពរកប្រាក់ចំណូលនិងអត្រាកំណើនប្រាក់ចំណូលដែលត្រូវបានប្រើប្រាស់ដោយវិនិយោគិននៅពេលដែលប្រៀបធៀបជម្រើសវិនិយោគ និងអ្នកប្រើផ្សេងទៀតក្នុងការវិនិច្ឆ័យពីសក្តានុពលនៃសហគ្រាសពាណិជ្ជកម្ម។
- ❖ ការព្យាករណ៍ពីការក្សីយធន និងការបរាជ័យ(Prediction of bankruptcy and failure): ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ គឺជាឧបករណ៍ដ៏សំខាន់មួយក្នុងការវាយតម្លៃ និងព្យាករណ៍ភាពក្សីយធន និង ប្រូបាប៊ីលីតេ

[8] Martin G. Jangles et al., Economic and Finance Analysis 2004 (ការវិភាគសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) , បោះពុម្ពលើកទី៣)

នៃភាពបរាជ័យរបស់អាជីវកម្ម។

- ❖ ការវាយតម្លៃពីប្រសិទ្ធភាពប្រតិបត្តិការ (Assessment of the operational efficiency): ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ជួយវាយតម្លៃពីប្រសិទ្ធភាពប្រតិបត្តិការនៃការគ្រប់គ្រងរបស់ក្រុមហ៊ុនមួយ។ លទ្ធភាពជាក់ស្តែងរបស់ក្រុមហ៊ុនដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចប្រៀបធៀបទៅនឹងស្តង់ដារមួយចំនួនដែលបានកំណត់ពីមុន ហើយភាពលំអៀងរវាងស្តង់ដារ និងការអនុវត្តជាក់ស្តែងអាចត្រូវបានប្រើជាសូចនាករនៃប្រសិទ្ធភាពរបស់ការគ្រប់គ្រង។[9]

១.៥.ឧបករណ៍ក្នុងការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

យើងប្រើយើងប្រើប្រាស់ឧបករណ៍ផ្សេងៗ ដើម្បីធ្វើការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ប៉ុន្តែឧបករណ៍ក្នុងការវិភាគរបាយការណ៍ហិរញ្ញវត្ថុដែលប្រើប្រាស់ញឹកញាប់ជាងគេមានបី គឺការវិភាគតាមជួរដេក (Horizontal Analysis), ការវិភាគតាមជួរឈរ (Vertical Analysis) និងការវិភាគតាមអនុបាត (Ratio Analysis)។

១.៥.១. ការវិភាគរបាយការណ៍ហិរញ្ញវត្ថុតាមជួរដេក (Horizontal Analysis)

ការវិភាគការវិភាគរបាយការណ៍ហិរញ្ញវត្ថុតាមជួរដេក (Horizontal Analysis) ឬអាចហៅម្យ៉ាងទៀតថា ការវិភាគតាមនិន្នាការ (Trend Analysis) គឺជាវិធីសាស្ត្រមួយសម្រាប់វាយតម្លៃទៅលើការប្រែប្រួលទិន្នន័យនៃគណនីនីមួយៗ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ពីកំឡុងពេលមួយទៅកំឡុងពេលមួយទៀត។ គោលបំណង នៃការវិភាគនេះ ដើម្បីឲ្យដឹងពីមូលហេតុនៃការកើនឡើង ឬថយចុះរបស់គណនីនីមួយៗ។ ចំពោះ លទ្ធផលនៃការវិភាគនេះ អាចត្រូវបានដាក់បង្ហាញជាចំនួន និងជា%។[10]

ការវិភាគតាមជួរដេកអនុវត្តន៍តាមរូបមន្ត ៖

$$\text{Current Change in Amount} = \text{Current year amount - Base year amount}$$

$$\text{Change in presentage (\%)} = \frac{\text{Current year amount - Base year amount}}{\text{Base year amount}}$$

[9] ប្រភព khemsaritheducation (wordpress.com) ចូលទស្សនាថ្ងៃ២០ មេសា ២០២៤

[10] ប្រភព Jerry J. Weygandt, Paul D. Kimmel, Donald E. Kieso, Financial Accounting [គណនេយ្យហិរញ្ញវត្ថុ], បោះពុម្ពលើកទី 2 (2013) ទំព័រ 689 ។

១.៥.២. **ការវិភាគរបាយការណ៍ហិរញ្ញវត្ថុតាមជួរឈរ** (Vertical Analysis)

ការវិភាគការវិភាគតាមជួរឈរ (Vertical Analysis) ឬអាចហៅម្យ៉ាងទៀតថា ការវិភាគលើទំហំរួម (Common-Size Analysis) គឺជាវិធីសាស្ត្រមួយក្នុងការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ដោយយកគណនីមួយ មានសមាមាត្រធៀបនឹងគណនីមួយផ្សេងទៀត។ ក្នុងការវិភាគតារាងតុល្យការ គណនីទ្រព្យសកម្មសរុប ត្រូវបានចាត់ទុកជាសមាមាត្រ ១០០ ហើយគណនីដទៃផ្សេងទៀតមានសមាមាត្រធៀបនឹងទ្រព្យសកម្ម សរុប។

ចំពោះរបាយការណ៍លទ្ធផល ចំណូលពីការលក់ ត្រូវបានចាត់ទុកជាសមាមាត្រ ១០០ ហើយ គណនីដទៃផ្សេងទៀតមានសមាមាត្រធៀបនឹងចំណូលពីការលក់។ ការវិភាគនេះមានសារៈសំខាន់ក្នុងការ បង្ហាញពីបម្លាស់ប្តូរផលធៀបនៃគណនីក្នុងក្រុមដូចជា ទ្រព្យ បំណុល ចំណូល និង ធាតុដទៃទៀត។ [11]

ការវិភាគតាមជួរឈរអនុវត្តន៍តាមរូបមន្ត៖

$$\text{Income statement Vertical Analysis \%} = \frac{\text{Each item in Income Statement}}{\text{Net Sales}}$$

$$\text{Balance Sheet Vertical Analysis \%} = \frac{\text{Each item in Balance Sheet}}{\text{Total Assets}}$$

១.៥.៣. **ការវិភាគដោយប្រើប្រាស់រូបមន្តអនុបាត**(Ratio Analysis)

ការវិភាគអនុបាតហិរញ្ញវត្ថុ គឺជាការគណនានូវអនុបាតដោយប្រើទិន្នន័យពីរបាយការណ៍ហិរញ្ញវត្ថុ និងការ

បកស្រាយនូវលទ្ធផលដែលទទួលបានពីការគណនា ដើម្បីកំណត់នូវទំនោរ និងការប្រៃប្រួលហើយត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការសម្រេចចិត្តរបស់អ្នកប្រើប្រាស់។

១.៥.៣.១ **អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលខ្លី** (Short-term Solvency Ratio)

អនុបាតសម្រាប់វាស់វែងពីលទ្ធភាពទូទាត់បំណុលរយៈពេលខ្លី ត្រូវបានប្រើប្រាស់សម្រាប់វាស់វែងពីសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការដោះស្រាយនូវបញ្ហាបំណុល ដែលក្រុមហ៊ុនបានខ្ចីពីម្ចាស់បំណុល មានដូចជាធនាគារ និងអ្នកផ្គត់ផ្គង់ជាដើម។ ម្យ៉ាងវិញទៀតក្នុងលក្ខខ័ណ្ឌ ដែលក្រុមហ៊ុនខ្វះលទ្ធភាពក្នុងការទូទាត់ បំណុល

[11] ប្រភព Jerry J. Weygandt, Paul D. Kimmel, Donald E. Kieso, Financial Accounting [គណនេយ្យហិរញ្ញវត្ថុ], បោះពុម្ពលើកទី 2 (2013) ទំព័រ 692 ។

ដល់ម្ចាស់បំណុលវាអាចនឹងធ្វើឲ្យមានការប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ក៏ដូចជាដំណើរការរបស់ក្រុមហ៊ុនយ៉ាងធ្ងន់ធ្ងរផងដែរ។[12]

ក. អនុបាតចរន្ត(Current Ratio)

អនុបាតចរន្ត គឺជាអនុបាតដែលត្រូវបានគេប្រើប្រាស់សម្រាប់វាស់វែងពីសាច់ប្រាក់របស់ក្រុមហ៊ុន និងសុវត្ថិភាពរបស់អាជីវកម្ម ហើយវាបង្ហាញនូវសមត្ថភាពរបស់ក្រុមហ៊ុនដើម្បីទូទាត់បំណុលរយៈពេលខ្លី។ បើលទ្ធផលនៃអនុបាតនេះមានទំហំធំជាង១ វាបញ្ជាក់ពីល្បឿនយ៉ាងលឿនរបស់ចលនាសាច់ប្រាក់នៅក្នុងក្រុមហ៊ុន។ ប្រសិនបើលទ្ធផលខាងលើមានកំរិតតូចជាង១ នោះបង្ហាញថាក្រុមហ៊ុននឹងជួបនូវបញ្ហាហិរញ្ញវត្ថុ។[13]

ខាងក្រោមនេះជារូបមន្តអនុបាតចរន្ត ៖

$$\boldsymbol{Current\ Ratio} = \frac{\text{Current Asset}}{\text{Current Liability}}$$

ខ. អនុបាតរហ័ស (Quick Ratio)

អនុបាតរហ័ស គឺជាអនុបាតដែលត្រូវបានប្រើដើម្បីវាស់វែងពីលទ្ធភាពរបស់អង្គភាពក្នុងការទូទាត់បំណុលរយៈពេលខ្លីដោយមិនចាំបាច់លក់សន្និធិ ឬទទួលយកនូវហិរញ្ញប្បទានពីខាងក្រៅ កាលណាអនុបាតនេះមានកំរិតខ្ពស់អង្គភាពកាន់តែមានស្ថានភាពហិរញ្ញវត្ថុល្អ ប៉ុន្តែបើវាមានកំរិតទាប នោះអង្គភាពនឹងមានការលំបាក ឬក៏រាំស្ទះសាច់ប្រាក់ក្នុងការទូទាត់បំណុល។[14]

អនុបាតរហ័ស មានរូបមន្តដូចខាងក្រោម ៖

$$\boldsymbol{Quick\ Ratio} = \frac{\text{Current Asset - Inventory}}{\text{Current Liability}}$$

[12] Berk J., DeMarco P. and Harford J (2002), Fundamentals of Corporate Finance បោះពុម្ពលើកទី២ , ទំព័រ ៣២

[13] ប្រភព Current Ratio Explained With Formula and Examples (investopedia.com) ចូលទស្សនាថ្ងៃទី ២០ មេសា ២០២៤

[14] ប្រភព Quick Ratio - Formula, Example, Calculate, Template (corporatefinanceinstitute.com) ចូលទស្សនាថ្ងៃទី ២០ មេសា ២០២៤

គ. អនុបាតសាច់ប្រាក់ (Cash Ratio)

អនុបាតសាច់ប្រាក់ គឺជាផលធៀបរវាងសាច់ប្រាក់នឹងបំណុលរយៈពេលខ្លី។ កាលណាតួលេខរបស់អនុបាតនេះកាន់តែធំវាមានលក្ខណៈល្អប្រសើរសម្រាប់ម្ចាស់បំណុលរយៈពេលខ្លី ប៉ុន្តែចំពោះអង្គភាពវិញអាចត្រូវបានគេវាយតម្លៃថាមានសាច់ប្រាក់ច្រើនទុកចោល មិនបានយកទៅប្រើប្រាស់ក្នុងការកចំណូល។[15] អនុបាតសាច់ប្រាក់មានរូបមន្តដូចខាងក្រោម ៖

$$Cash\ Ratio = \frac{\text{Cash}}{\text{Current Liability}}$$

១.៥.៣.២ អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលវែង (Long-term Solvency Ratio)

អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលវែង គឺជាអនុបាតដែលប្រើសម្រាប់វាស់វែងនូវកំរិតជាប់បំណុលរបស់អង្គភាព ជាពិសេសលទ្ធភាពរបស់អង្គភាពក្នុងការគោរពកាតព្វកិច្ចបំណុលក្នុងការកំណត់សង។ អនុបាតនេះរួមមាន ៖

ក. អនុបាតបំណុលសរុប (Total Debt Ratio)

អនុបាតបំណុលសរុប គឺជាអនុបាតដែលវាស់វែងកំរិតទ្រព្យសកម្មរបស់អង្គភាពដែលត្រូវបានផ្គត់ផ្គង់ដោយបំណុល។ បំណុលសរុបរួមបញ្ចូលទាំងបំណុលរយៈពេលខ្លី និងបំណុលរយៈពេលវែង។ ម្ចាស់បំណុលចង់ដឹងពីកំរិតបំណុលរបស់អង្គភាព ព្រោះថាបើអនុបាតនោះ កាន់តែទាបនោះកំរិតការពារនៃការខាតបង់របស់ម្ចាស់បំណុលកាន់តែខ្ពស់ ប្រសិនបើអង្គភាពត្រូវរំលាយ។ ចំណែកឯម្ចាស់ក្រុមហ៊ុនវិញគឺចង់ឱ្យអង្គភាពប្រើបំណុលនេះកាន់តែច្រើន ព្រោះវាអាចបង្កើនប្រាក់ចំណេញរំពឹងទុករបស់ពួកគេ។ ដូចច្នេះអ្នកគ្រប់គ្រងត្រូវសម្រេចចិត្តលើកំរិតបំណុលដែលក្រុមហ៊ុនគួរប្រើប្រាស់ ដើម្បីកុំឱ្យបង្កើនហានិភ័យនៃការគ្មានលទ្ធភាពសងបំណុលវិញ។[16] អនុបាតបំណុលសរុប មានរូបមន្តដូចខាងក្រោម ៖

$$Total\ Debt\ Ratio = \frac{\text{Total Debt}}{\text{Total Asset}}$$

[15] ប្រភព Cash Ratio: Definition, Formula, and Example (investopedia.com)ចូលទស្សនាថ្ងៃទី ២០ មេសា ២០២៤

[16] Eugene F. Brigham, Michel C. Ehrhardt (2002), Financial Management ទំព័រ 82

ខ. អនុបាតបំណុលធៀបនឹងមូលធន (Debt to Equity Ratio)

អនុបាតបំណុលធៀបនឹងមូលធន គឺជាអនុបាតវាស់វែងពី%នៃបំណុលធៀបនឹងមូលធនរបស់អង្គភាព ដើម្បីដឹងពីលទ្ធភាពសងត្រឡប់របស់មូលធន ប្រសិនបើអង្គភាពត្រូវការរំលាយ។ អង្គភាពដែលមាន បំណុលធៀបជាមួយមូលធនខ្ពស់ គឺទទួលបាននូវហានិភ័យខ្លាំងប្រសិនបើមានវិបត្តិសេដ្ឋកិច្ច ព្រោះទោះជាចំណូលរបស់អង្គភាពធ្លាក់ចុះក៏ដោយ ក៏អង្គភាពនៅតែមានកាតព្វកិច្ចសងការប្រាក់ និងប្រាក់ដើមដែលជំពាក់ដដែល។ ចំណែកឯមូលធនរបស់ម្ចាស់ភាគហ៊ុនវិញ អង្គភាពមិនមានកាតព្វកិច្ចសងប្រាក់វិនិយោគវិញឡើយ ហើយការបែងចែកភាគលាភអាចត្រូវបានពន្យា រហូតដល់ពេលដែលប្រាក់ចំណេញអង្គភាពងើបឡើងវិញ។[17] ខាងក្រោមនេះជារូបមន្តរបស់បំណុលធៀបនឹងមូលធន ៖

$$\boldsymbol{Debt\ to\ Equity\ Ratio} = \frac{\text{Total Debt}}{\text{Total Equity}}$$

គ. មេគុណមូលធន (Equity Multiplier)

មេគុណមូលធន គឺជាសមាមាត្រអនុភាពហិរញ្ញវត្ថុមួយដែលត្រូវបានគណនាដោយបែងចែកទ្រព្យសកម្មសរុបដោយមូលធនភាគទុនិក។ វានឹងបង្ហាញអំពីទ្រព្យសកម្មប៉ុន្មានដុល្លារក្នុងមូលធនមួយដុល្លារ។ ករណីមេគុណនេះខ្ពស់ធ្វើឲ្យអនុភាពហិរញ្ញវត្ថុនេះទាប។[18] អនុបាតមូលធន មានរូបមន្តដូចខាងក្រោម ៖

$$\boldsymbol{Equity\ Multiplier(EM)} = \frac{\text{Total Asset}}{\text{Total Equity}}$$

ឃ. អនុបាតចំនួនដងនៃការចំណាយការប្រាក់ (Times Interest Earned Ratio)

អនុបាតនៃចំនួនដងនៃការចំណាយការប្រាក់ គឺប្រើសម្រាប់វាស់ពីលទ្ធភាព ដែលប្រាក់ចំណេញពីប្រតិបត្តការរបស់អង្គភាពអាចធ្លាក់ចុះ មុននឹងអង្គភាពមិនមានលទ្ធភាពសងការប្រាក់តាមកាលកំណត់ អាចនាំឲ្យមានការប្តឹងពីម្ចាស់បំណុល ហើយអាចឈានទៅរកការក្ស័យធនផងដែរ។ អនុបាតនេះត្រូវបាន គណនា

[17] Eugene F. Brigham, Michel C. Ehrhardt (2002), Financial Management ទំព័រ 252

[18] ប្រភព Equity Multiplier Ratio | Analysis | Formula | Example (myaccountingcourse.com) ចូលទស្សនាថ្ងៃទី ២០ មេសា ២០២៤

ដោយចែកប្រាក់ចំណេញមុននឹងចំណាយការប្រាក់ និងពន្ធជាមួយនឹងចំណាយការប្រាក់។ អនុបាតចំនួនដងនៃការចំណាយការប្រាក់ មានរូបមន្តដូចខាងក្រោម ៖

$$Time\ Interest\ Earned\ Ratio = \frac{\text{Earning before Interest and Taxs}}{\text{Interest}}$$

១.៥.៣.៣ អនុបាតនៃលទ្ធភាពប្រើប្រាស់ទ្រព្យសកម្ម (Asset Utilization)

អនុបាតនៃលទ្ធភាពប្រើប្រាស់ទ្រព្យសកម្ម គឺត្រូវបានប្រើប្រាស់ដើម្បីវាស់វែងការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសកម្មក្នុងការស្វែងរកប្រាក់ចំណូលរបស់ក្រុមហ៊ុន។ អនុបាតនៃលទ្ធភាពប្រើប្រាស់ទ្រព្យសកម្មរួមមាន ៖

ក.អនុបាតបង្វិលជុំនៃសន្និធិ (Inventory Turnover)

អនុបាតបង្វិលជុំនៃសន្និធិ ជាអនុបាតដែលបង្ហាញពីចំនួនដងដែលអង្គភាពបញ្ចេញសន្និធិ ហើយទិញចូល ឬផលិតសន្និធិទាំងនោះឡើងវិញក្នុងកំឡុងពេលណាមួយ។ អនុបាតនេះអាចជួយអ្នកគ្រប់គ្រងអង្គភាព ធ្វើការសម្រេចចិត្តកាន់តែមានប្រសិទ្ធភាពលើតម្លៃ ដំណើរការផលិត ការធ្វើទីផ្សារ និងនាំចូលនូវសន្និធិថ្មីផងដែរ។ កាលណាលទ្ធផលដែលទទួលបានពីការគណនាអនុបាតនេះកាន់តែទាបបង្ហាញពីការលក់ខ្សោយ និងសន្និធិមានចំនួនលើសតម្រូវការ ប៉ុន្តែបើលទ្ធផលវាកាន់តែខ្ពស់មានន័យថាការលក់កាន់តែមានភាពខ្លាំងនិងសន្និធិអាចផ្គត់ផ្គង់ស្របតម្រូវការ។[19] អនុបាតនេះមានរូបមន្តដូចខាងក្រោម ៖

$$Inventory\ \ Turnover = \frac{\text{Cost of Goods sold}}{\text{Average Inventory}}$$

ខ. អនុបាតចំនួនថ្ងៃលក់សន្និធិ (Day's Sale in Inventory)

អនុបាតចំនួនថ្ងៃនៃការលក់សន្និធិ ជាអនុបាតដែលបង្ហាញពីចំនួនថ្ងៃជាមធ្យមដែលត្រូវបានចំណាយពេលសម្រាប់ អង្គភាពមួយក្នុងការលក់ចេញនូវសន្និធិ។ អនុបាតនេះជាមូលដ្ឋានមួយសម្រាប់អ្នកគ្រប់គ្រងប្រើប្រាស់ដើម្បីកំណត់នូវប្រសិទ្ធភាពនៃការលក់ ហើយប្រសិនបើតួលេខនៃអនុបាតនេះខ្ពស់ មានន័យថាអង្គភាព

[19] ប្រភព Inventory turnover Ratios : What is it , how it works, and formula (២០ មេសា ២០២៤)

មួយនោះគ្រប់គ្រងសន្និធិមិនបានល្អទេ ឬអាចមានសន្និធិដែលពិបាកលក់ចេញ ។[20] អនុបាតនេះមានរូបមន្ត ដូចខាងក្រោម ៖

$$Day's\ Sale\ in\ Inventory = \frac{365\ \text{days}}{\text{Inventory Turnover}}$$

គ. អនុបាតបង្វិលជុំនៃឥណទេយ្យ (Account Receivable Turnover)

អនុបាតបង្វិលជុំនៃឥណទេយ្យ គឺជាអនុបាតមួយដែលត្រូវបានប្រើប្រាស់ដើម្បីវាស់វែងពីចំនួនដងដែលឥណទេយ្យត្រូវបានបង្វិលក្នុងមួយឆ្នាំ និងបង្ហាញពីកំរិតប្រសិទ្ធភាពរបស់អង្គភាពក្នុងការប្រមូលឥណនេយ្យ ឬប្រាក់ដែលអតិថិជនជំពាក់។ Receivable Turnover មានកម្រិតទាបបង្ហាញថាការប្រួលឥណទេយ្យរបស់អង្គភាពមានភាពខ្សោយ និងមានចំនួនអតិថិជនច្រើន ដែលសងបំណុលមិនទាន់កាលកំណត់។[21] អនុបាត នេះអាចគណនាដូចខាងក្រោម ៖

$$Account\ Receivable\ Turnover = \frac{\text{Net Credit Sale}}{\text{Average Account Receivable}}$$

ឃ. អនុបាតចំនួនថ្ងៃដែលឥណទេយ្យសង (Day's Sale in Account Receivable)

អនុបាតដែលចំនួនថ្ងៃដែលឥណទេយ្យសង គឺជាអនុបាតដែលបង្ហាញពីចំនួនថ្ងៃជាមធ្យមដែលត្រូវបាន ចំណាយពេលសម្រាប់សងអង្គភាពមួយ ក្នុងការប្រមូលប្រាក់ជំពាក់ពីអតិថិជន បន្ទាប់ពីការលក់បានកើតឡើង។ អនុបាតនេះអាចវាស់វែងពីកម្រិតដែលអតិថិជនសងប្រាក់លឿន ឬយឺត និងប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទេយ្យរបស់អង្គភាពមួយ។[22] អនុបាតនេះមានរូបមន្តដូចខាងក្រោម ៖

[20] ប្រភព Days Sales in Inventory: Formula, Definition & More | Flowspace (២០ មេសា ២០២៤)

[21] ប្រភព Receivables Turnover Ratio: Formula, Importance, Examples, and Limitations (investopedia.com)(២០ មេសា ២០២៤)

[22] ប្រភព Days Sales Outstanding (DSO): Meaning in Finance, Calculation, and Applications (investopedia.com) (ចូលទស្សនាថ្ងៃទី២០ មេសា ២០២៤)

$$Day'Sale\ in\ Account\ Receivable = \frac{365\ days}{Account\ Receivable\ Turnover}$$

ង. អនុបាតដើមទុនចរន្តសុទ្ធ (Net Working Capital Turnover)

អនុបាតដើមទុនចរន្តសុទ្ធ ប្រើសម្រាប់វាស់វែងនូវប្រសិទ្ធរបស់អង្គភាពក្នុងការស្វែងរកប្រាក់ចំណូលដោយប្រើប្រាស់ដើមទុនចរន្តសុទ្ធដែលខ្លួនមាន។ យើងអាចនិយាយម្តងទៀតថាជាប្រាក់ចំណូលដែលទទួលបានពីទ្រព្យសកម្មរយៈពេលខ្លីសុទ្ធដែលត្រូវបានដកជាមួយបំណុលរយៈពេលខ្លីរួច។ អង្គភាពដែលមាន NWC Turnover ខ្ពស់មានន័យថាអង្គភាពនោះបានប្រើប្រាស់ទ្រព្យសកម្មរយៈពេលខ្លីសុទ្ធបានល្អជាងក្រុមហ៊ុន ដែលមាន NWC Turnover ទាបជាង។[23]

$$Net\ Working\ Capital\ Turnover = \frac{Net\ Sales}{Net\ working\ Capital}$$

ច. អនុបាតបង្វិលជុំនៃទ្រព្យសកម្មរយៈពេលវែង (Fixed Asset Turnover)

អនុបាតបង្វិលជុំនៃទ្រព្យសកម្មរយៈពេលវែង បង្ហាញពីការវាស់វែងនូវប្រសិទ្ធភាពក្នុងការប្រើប្រាស់ និងការគ្រប់គ្រងនូវទ្រព្យសកម្មរយៈពេលវែង ដែលក្រុមហ៊ុនទទួលបានការវិនិយោគលើទ្រព្យសកម្មរយៈពេលវែង។ បើលទ្ធផលដែលទទួលបានកាន់តែខ្ពស់មានន័យថា អង្គភាពមានសមត្ថភាពនៅក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសកម្មរយៈពេលវែងឱ្យអស់លទ្ធភាព តែបើកម្រិតទាបវិញនោះ មានន័យថាការប្រើប្រាស់ និងការគ្រប់គ្រងទ្រព្យសកម្មរបស់អង្គភាពគឺមិនមានប្រសិទ្ធភាពឡើយ។[24]

$$Fixed\ Asset\ Turnover = \frac{Net\ Sales}{Fixed\ Asset}$$

[23] ប្រភព Working Capital Turnover Ratio: Meaning, Formula, and Example (investopedia.com) (ចូលទស្សនាថ្ងៃទី ២០ មេសា ២០២៤)

[24] Ross Westerfield Jordan (2006)., Fundamentals of Corporate Finance' ‘ បោះពុម្ពលើកទី៨

ឆ. អនុបាតការបង្វិលទ្រព្យសកម្មសរុប (Total Asset Turnover)

អនុបាតការបង្វិលទ្រព្យសកម្មសរុប គឺប្រើសម្រាប់វាស់វែងនូវ ប្រសិទ្ធភាពរបស់អង្គភាពក្នុងការស្វែងរកប្រាក់ចំណូលដោយប្រើប្រាស់ទ្រព្យសកម្មដែលខ្លួនមាន។ យើងអាចនិយាម្យ៉ាងទៀតថាប្រាក់ចំណូលដែលទទួលបានពីទ្រព្យសកម្មមួយដុល្លារ។ អង្គភាពដែលមាន Total Asset Turnover ខ្ពស់មានន័យថាអង្គភាពនោះ បានប្រើប្រាស់ទ្រព្យសកម្មបានល្អជាងក្រុមហ៊ុនដែលមាន Total Asset Turnover ទាបជាង។[25] អនុបាតនេះគណនាតាម៖

$$Total\ Asset\ Turnover = \frac{\text{Net Sales}}{\text{Total Asset}}$$

១.៥.៣.៤. អនុបាតនៃលទ្ធភាពស្វែងរកប្រាក់ចំណេញ (Profitability Ratio)

គ្រប់អង្គភាពអាជីវកម្មទាំងអស់ មានគោលដៅចំបងមួយគឺប្រាក់ចំណេញ។ អាស្រ័យហេតុនេះ ហើយទើបពួកគេខិតខំប្រឹងប្រែងធ្វើយ៉ាងណាឱ្យអាជីវកម្មរបស់ពួកគេមានប្រាក់ចំណេញកាន់តែខ្ពស់គឺកាន់តែប្រសើរ។ ដើម្បីឱ្យដឹងពីប្រសិទ្ធភាពនៃការបង្កើតប្រាក់ចំណេញបានកម្រិតណា គេប្រើប្រាស់អនុបាតមួយចំនួនដូច ខាងក្រោម៖

ក. អនុបាតប្រាក់ចំណេញសុទ្ធ (Profit Margin Ratio)

អនុបាតប្រាក់ចំណេញសុទ្ធ គឺជាផលធៀបរវាងប្រាក់ចំណេញសុទ្ធធៀបជាមួយនឹងចំណូលនៃការលក់របស់ក្រុមហ៊ុនសរុប។ អនុបាតនេះវាស់វែងពីលទ្ធភាពស្វែងរកប្រាក់ចំណេញពិតដែលក្រុមហ៊ុនទទួលបាន រៀងរាល់មួយដុល្លារនៃប្រាក់ចំណេញសុទ្ធ។ ជាទូទៅរាល់អ្នកវិនិយោគទុននឹងម្ចាស់ភាគហ៊ុនគឺតែងតែមានការចាប់អារម្មណ៍ និងធ្វើការវាយតម្លៃពីប្រាក់ចំណេញដល់ក្រុមហ៊ុន។ បើអនុបាតនេះកាន់តែធំគឺកាន់តែល្អ ពីព្រោះ បានបង្ហាញថាក្រុមហ៊ុនទទួលបានប្រាក់ចំណេញកាន់តែច្រើនពីប្រតិបត្តិការរបស់ខ្លួន។[26] វាត្រូវបានគេយកមកគណនាដោយផ្អែកលើរូបមន្តដូចខាងក្រោម ៖

$$Profit\ Margin\ (PM) = \frac{\text{Net Income}}{\text{Net Sales}}$$

[25] Belverd E. Needles and Marian Powersm (2007), Financial Accounting ទំព័រ 252

[26] Peter S. Rose and Sylvia C. Hugin, 2010, Bank Management and Financial Service, Eight Edition, ទំព័រ ១៧៤

ខ. អនុបាតផលចំណេញពីទ្រព្យសកម្ម (Return on Assets)

អនុបាតផលចំណេញនៃទ្រព្យសកម្ម គឺជាផលធៀបរវាងប្រាក់ចំណេញសុទ្ធជាមួយនឹងទ្រព្យសកម្មសរុបនៅក្នុងគ្រា ដើម្បីចង់ដឹងពីប្រាក់ចំណេញដែលអាជីវកម្មមានលទ្ធភាពបង្កើតដោយប្រើទ្រព្យសកម្មរបស់ខ្លួន។ អនុបាតនេះមានតម្លៃកាន់តែធំកាន់តែល្អប្រសើរ ព្រោះវាបង្ហាញពីប្រសិទ្ធភាពនៃការប្រើប្រាស់ទ្រព្យសកម្មរបស់ ក្រុមហ៊ុនក្នុងការបង្កើតប្រាក់ចំណេញកាន់តែប្រសើរ។ ប៉ុន្តែបើអនុបាតនេះកាន់តែទាប មានន័យថាការប្រើ ប្រាស់ទ្រព្យសកម្មរបស់ក្រុមហ៊ុនគ្មានប្រសិទ្ធភាពក្នុងការបង្កើនប្រាក់ចំណេញ។[27]

$$\textbf{Return on Assets} = \frac{\text{Net Income}}{\text{Total Asset}}$$

គ. អនុបាតផលចំនេញធៀបនឹងមូលធន (Return on Equity)

អនុបាតផលចំណេញធៀបនឹងមូលធន គឺជាផលធៀបរវាងប្រាក់ចំណេញសុទ្ធធៀបជាមួយនឹងមូលធនសរុប ដើម្បីវាស់វែងប្រាក់ចំណេញ ដែលរកបានដោយអង្គភាពតាមរយៈការប្រើប្រាស់មូលធនមួយដុល្លារសម្រាប់វិនិយោគ គេអាចទទួលបានប្រាក់ចំណេញប៉ុន្មាន។ នៅក្នុងការគណនា ប្រសិនបើលទ្ធភាពនៃអនុបាតកាន់តែធំគឺកាន់តែល្អ ព្រោះមានន័យថាក្រុមហ៊ុនប្រើប្រាស់មូលធនក្នុងការបង្កើតប្រាក់ចំណេញមានប្រសិទ្ធភាពខ្ពស់ ផ្ទុយមកវិញប្រសិនបើលទ្ធភាពនៃអនុបាតកាន់តែតូចនោះបញ្ជាក់ថាការប្រើប្រាស់មូលធនរបស់ក្រុមហ៊ុនគ្មានប្រសិទ្ធភាព។[28] ខាងក្រោមនេះជារូបមន្តសម្រាប់គណនាអនុបាតប្រាក់ចំណេញធៀបនឹងមូលធន ៖

$$\textbf{Return on Equity} = \frac{\text{Net Income}}{\text{Total Equity}}$$

[27] ប្រភព Return on Assets (ROA): Formula and "Good" ROA Defined (investopedia.com) (ចូលទស្សនាថ្ងៃទី ២០ មេសា ២០២៤)

[28] ប្រភព Return on Equity (ROE) - What Is It, Formula, Vs RoCE, Examples (wallstreetmojo.com) (ចូលទស្សនាថ្ងៃទី ២០ មេសា ២០២៤)

១.៥.៣.៥. អនុបាតទីផ្សារ (Market Ratio)

ក. អនុបាតថ្លៃជាមួយនឹងប្រាក់ចំណេញ) (Price-Earnings Ratio)

អនុបាតថ្លៃជាមួយនឹងប្រាក់ចំណេញ គឺជាផលធៀបតម្លៃទីផ្សារនៃភាគហ៊ុនជាមួយនឹងប្រាក់ចំណេញក្នុងមួយភាគហ៊ុនរបស់ក្រុមហ៊ុន។ ពីតម្លៃទីផ្សារដែលអ្នកវិនិយោគត្រូវចំណាយក្នុងការទិញភាគហ៊ុនដើម្បីទទួលបាន

ប្រាក់ចំណេញមួយដុល្លារ។[29] ខាងក្រោមនេះគឺជារូបមន្តដើម្បីចង់គណនាអនុបាតថ្លៃជាមួយនឹងប្រាក់ ចំណេញ៖

$$Price\ Earning\ Ratio = \frac{\text{Market price}}{\text{Earnings Per Share}}$$

ខ. អនុបាតទីផ្សារ (Market-to-book Ratio)

អនុបាតទីផ្សារ គឺជាអនុបាតដែលត្រូវបានប្រើដើម្បីវាស់វែងពីតម្លៃភាគហ៊ុនរបស់អង្គភាពដោយប្រៀបធៀបតម្លៃទីផ្សាររបស់វាជាមួយនឹងតម្លៃដែលបានកត់ត្រាក្នុងបញ្ជី។ កាលណាអនុបាតនេះកាន់តែខ្ពស់មានន័យថា តម្លៃទីផ្សារភាគហ៊ុនរបស់អង្គភាពមានតម្លៃកាន់តែខ្ពស់ជាងតម្លៃភាគហ៊ុនដែលបានកត់ត្រាក្នុងបញ្ជី។[30] អនុបាតទីផ្សារមានរូបមន្តដូចខាងក្រោម ៖

$$Market\ to\ book\ ratio = \frac{\text{Market Value per share}}{\text{Book Value Per share}}$$

[29] ប្រភព Price-to-Earnings (P/E) Ratio: Definition, Formula, and Examples (investopedia.com) (ចូលទស្សនាថ្ងៃទី ២០ មេសា ២០២៤)

[30] ប្រភព Market to Book Ratio- What It Is, Formula, Calculation. (wallstreetmojo.com) (ចូលទស្សនាថ្ងៃទី ២០ មេសា ២០២៤)

ជំពូកទី២

ស្ថានភាពទូទៅរបស់

ក្រុមហ៊ុន Tesla, Inc.

ជំពូកទី២
ស្ថានភាពទូទៅរបស់ក្រុមហ៊ុន Tesla, Inc.

២.១.ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន Tesla, Inc.

នៅថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០២១ ក្រុមហ៊ុន Tesla, Inc. បានផ្លាស់ប្តូរទីស្នាក់ការកណ្តាលសាជីវកម្មរបស់ខ្លួនទៅកាន់ Gigafactory Texas នៅ 13101 Harold Green Road, Austin, Texas 78725″ ក្រុមហ៊ុនបានសរសេរថា ឯកសាររបស់ (Securities and Exchange Commission) SEC ត្រូវបានចុះហត្ថលេខាដោយប្រធានផ្នែកហិរញ្ញវត្ថុ Zachary J. Kirkhorn ។ ប៉ុន្តែនៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២៣ ធ្វើឲ្យគ្រប់គ្នាភ្ញាក់ផ្អើល លោក Musk និង Gavin Newsom អភិបាលគណបក្សប្រជាធិបតេយ្យនៃរដ្ឋកាលីហ្វ័រញ៉ា បានរៀបចំព្រឹត្តិការណ៍មួយរួមគ្នាដើម្បីប្រកាសថាក្រុមហ៊ុន Tesla នឹងតាំងទីស្នាក់ការកណ្តាលផ្នែកវិស្វកម្មសកលរបស់ខ្លួននៅ Palo Alto ចម្ងាយ ៤0 នាទីភាគខាងត្បូងនៃទីក្រុង San Francisco ។[31]

រូបភាពទី១ ៖ ទីស្នាក់ការកណ្តាលសាជីវកម្មរបស់ក្រុមហ៊ុន Tesla នៅ Gigafactory Texas

[31] ប្រភព https://www.thestreet.com/technology/texas-or-california-tesla-clarifies-where-its-headquartered (ចូលទស្សនាថ្ងៃទី០៥ ឧសភា ២០២៤)

រូបភាពទី២ ៖ ទីស្នាក់ការកណ្តាលផ្នែកវិស្វកម្មសកលរបស់ក្រុមហ៊ុន Tesla នៅ Palo Alto

២.២. ប្រវត្តិសង្ខេបក្រុមហ៊ុន Tesla, Inc.

